ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : [illegible]

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្តូរបរិក្ខារប្រព័ន្ធបណ្តាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី០៨ ខែឧសភា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉ោ០០ ដល់ម៉ោង១៣ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិត្រពាំងស្វាយ ក្នុងសង្កាត់ភ្នំពេញថ្មី ភូមិបន្លាស្អិត ក្នុងសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងកែលម្អខ្សែបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

២. ថ្ងៃសុក្រទី០៩ ខែឧសភា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងលេខ P042 ស្ថិតនៅភូមិជ្រៃកោង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃព្រីងខាងត្បូង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីផ្លាស់ប្តូរបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៣. ថ្ងៃសៅរ៍ទី១០ ខែឧសភា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់ច្បារអំពៅ២ រហូតដល់សង្កាត់វាលស្បូវ ខណ្ឌមានជ័យ (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៦ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដើមគរ ភូមិព្រែកតាសេក ក្នុងសង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ និង (៣) ចាប់ពីម៉ោង០៨ម៉០០ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវេងស្រេង ចាប់ពីភូមិទ្រា៣ រហូតដល់មុខទីតាំងសួនឧស្សាហកម្មវឌ្ឍនៈ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវេងស្រេង ។

៤. ថ្ងៃអាទិត្យទី១១ ខែឧសភា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិកាកាប ភូមិត្រពាំងជ្រៃ ភូមិព្រៃសាលា ភូមិក្បាលដំរី ក្នុងសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៥. ថ្ងៃសៅរ៍ទី១០ និងថ្ងៃអាទិត្យទី១១ ខែឧសភា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ រហូតដល់ឃុំសំរោងធំ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ដើម្បីរុះរើគន្លងខ្សែបណ្តាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវកោះនរាណ៍ ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី.០៥.....ខែឧសភា.ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ_រតនៈ**